# សហព័ន្ធស្រូវអង្ករកម្ពុជា

## សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសបុគ្គលិក

សហព័ន្ធស្រូវអង្ករកម្ពុជា(ស.អ.ក) ជាស្ថាប័នមិនគិតប្រាក់ចំនេញឈានមុខមួយក្នុងវិស័យឯកជន ដោយមានកាតព្វកិច្ចចម្បងក្នុងការជំរុញ និងពង្រឹងគ្រប់ភាគីពាក់ព័ន្ធសំខាន់ៗក្នុងខ្សែចង្វាក់វិស័យស្រូវអង្ករ ជាពិសេស កសិករ សហគមន៍កសិកម្ម ម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងក្រុមហ៊ុននាំចេញអង្ករ ដោយបានទទួលស្គាល់ដោយអនុក្រឹត្យលេខ ២២៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៤ ដោយរាជរដ្ឋាភិបាល។

ដើម្បីឆ្លើយតបទៅនឹងការអនុវត្តនូវផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពរយៈពេល៥ឆ្នាំរបស់សហព័ន្ធស្រូវអង្ករកម្ពុជា ក៏ដូចជាជួយគាំទ្រដល់តួនាទីសេដ្ឋកិច្ចនិងសង្គមជាតិព្រមទាំងគោលនយោបាយរបស់រាជរដ្ឋាភិបាល សហព័ន្ធស្រូវអង្ករកម្ពុជាត្រូវការជ្រើសរើសអ្នកដែលមានជំនាញនិងបទពិសោធខ្ពស់ដើម្បីជួយសម្របសម្រួល និងអនុវត្តការតាមផែនការ។ បេក្ខជនគួរមានការយល់ដឹងខ្ពស់អំពីបច្ចេកទេសអំពីបញ្ហាប្រឈមទាំងឡាយក្នុងវិស័យស្រូវអង្ករ និងយល់ច្បាស់ពីកាតព្វកិច្ចដែលជាបន្ទុកចំពោះមុខរបស់ខ្លួន។ បេក្ខជនត្រូវមានបទពិសោធន៍ក្នុងការដឹកនាំនិងគ្រប់គ្រងក្នុងការផ្តួចផ្តើមរៀបចំការងារបន្តដោយជោគជ័យ ហើយត្រូវជាបុគ្គលដែលមានសមត្ថភាពដឹកនាំខ្ពស់មានបុគ្គលិកលក្ខណៈនិងមានជំនាញក្នុងការធ្វើទំនាក់ទំនងល្អព្រមទាំងមានឆន្ទៈខ្ពស់ក្នុងការធ្វើការងារជាក្រុម។ បេក្ខជនគួរជាអ្នកដែលមានសមត្ថភាពដោះស្រាយបញ្ហាខ្ពស់បំផុត ប្រកបដោយជំនាញក្នុងការវិភាគ និងភាពជាអ្នកដឹកនាំ។ ភាពស្ទាត់ជំនាញក្នុងការប្រើប្រាស់ភាសាខ្មែរនិងអង់គ្លេស។ សមត្ថភាពប្រើប្រាស់ភាសាបរទេសទីបីផ្សេងទៀតដូចជា ភាសារចិនឬបារាំងនឹងមានអាទិភាព។

បេក្ខជន ត្រូវមានសញ្ញាបត្រនិងបទពិសោធន៍ការងារពាក់ព័ន្ធយ៉ាងហោចណាស់២ទៅ៥ឆ្នាំ ដោយមានការយល់ដឹងយ៉ាងល្អប្រសើរនូវរាល់បញ្ហាបច្ចេកទេស វប្បធម៌ និងបទបញ្ញាត្តិផ្សេងៗ ដែលពាក់ព័ន្ធ។

ការជ្រើសរើសប្រធានផ្នែក បុគ្គលិកផ្នែក និងតំណាងប្រចាំតំបន់ រួមមាន៖

**១. ផ្នែកការងាររោងម៉ាស៊ីនកិនស្រូវ និងឃ្លាំងស្តុក (Department of Milling and Storage)។**

**២. បុគ្គលិកផ្នែកការនាំចេញ និងទីផ្សារអន្តរជាតិ (Officer of Department Global Market)។**

**៣. បុគ្គលិកផ្នែកពូជ និងការងារកសិករ (Officer of Department of Seed and Farming)។**

**៤. តំណាងចំនួន៥រូប ប្រចាំតំបន់ទាំង៥ របស់សហព័ន្ធ(CRF's 5 Zones 5 Representatives)។**

### ១. ប្រធានផ្នែកការងាររោងម៉ាស៊ីនកិនស្រូវ និងឃ្លាំងស្តុកៈ

ប្រធានផ្នែកការងាររោងម៉ាស៊ីនកិនស្រូវនិងឃ្លាំងស្តុក តម្រូវឲ្យមានចំណេះដឹងខាងបច្ចេកទេស និងការអនុវត្តន៍ជាក់ស្តែងក្នុងការកិននិងកែច្នៃអង្ករ។ អ្នកមានភារកិច្ចក្នុងការជំរុញជួយចម្របសម្រួលរាល់បញ្ហាប្រឈមនានាដែលប៉ះពាល់ដល់ម្ចាស់រោងម៉ាស៊ីនកិនស្រូវ ដូចជា ការផ្គត់ផ្គង់ស្រូវ ការកិន ការកែច្នៃ ទីផ្សារក្នុងស្រុកនិងទីផ្សារនាំចេញ។ អ្នកតម្រូវឲ្យមានចំណេះដឹងទូលំទូលាយទាក់ទងនឹងបច្ចេកទេស និងការគ្រប់គ្រងការសម្ងួតស្រូវ ការទុកដាក់ ការកិននិងកែច្នៃ ព្រមទាំងត្រូវផ្តល់អនុសាសន៍ណែនាំដើម្បីបង្កើនផលិតភាព គុណភាព និងភាពប្រកួតប្រជែងរបស់រោងម៉ាស៊ីនកិនស្រូវ។ការងារនេះទាមទារការចុះអនុវត្តការងារដោយផ្ទាល់តាមបណ្តាខេត្ត ហើយដើរតួនាទីជាអន្តរបុគ្គលរបស់សហព័ន្ធជាមួយនឹងម្ចាស់ម៉ាស៊ីនកិនស្រូវ តំណាងសមាគមន៍ម៉ាស៊ីនកិនស្រូវ ក៏ដូចជាស្ថាប័នរដ្ឋ និងអង្គការពាក់ព័ន្ធនានា។

**<u>លក្ខខណ្ឌសមត្ថភាព និងចំណេះដឹងៈ</u>**

- មានយល់ដឹងខ្ពស់ពីវិស័យស្រូវអង្ករ ជាពិសេសផ្នែកសំភារៈបរិក្ខារម៉ាស៊ីនកិនស្រូវ
- បានបញ្ចប់សកលវិទ្យាល័យផ្នែកវិស្វកម្ម ឬផ្នែកត្រួតពិនិត្យស្បៀងអាហារ ឬមានបទពិសោធន៍ត្រួតពិនិត្យគុណភាព និងអនាម័យក្នុងរោងម៉ាស៊ីនកិនស្រូវច្រើនឆ្នាំដែលអាចមានតម្លៃស្មើ
- មានចំណេះដឹងទូលំទូលាយទាក់ទងនឹងបច្ចេកទេស និងការគ្រប់គ្រងការសម្ងួតស្រូវ ម៉ាស៊ីនសម្ងួត ឃ្លាំងស្តុក ការទុកដាក់ និងការកិនកែច្នៃ
- មានសមត្ថភាពធ្វើការងារជាក្រុម និងក្រោមសំពាធការងារ។

### ២. បុគ្គលិកផ្នែកជំរុញ និងផ្សព្វផ្សាយទីផ្សារអន្តរជាតិៈ

ជំនួយការឲ្យផ្នែកនាំចេញនិងទីផ្សារអន្តរជាតិមានការយល់ដឹងក្នុងការសម្របសម្រួលខាងបច្ចេកទេស និងការអនុវត្តន៍ជាក់ស្តែងក្នុងការនាំចេញអង្ករ គិតតាំងពីការរៀបចំបញ្ចូល និងដឹកជញ្ជូនទំនិញពីរោងម៉ាស៊ីនកិនស្រូវទៅកំពង់ផែ ដោយរួមមានចំណេះដឹងក្នុងកាតព្វកិច្ចនិងបទបញ្ញត្តិ កិច្ចសន្យាលក់លក្ខខណ្ឌទូទាត់អន្តរជាតិ Inco terms បែបបទការដឹកជញ្ជូន និងទីផ្សារអន្តរជាតិ។ តួនាទីរបស់ជំនួយការផ្នែកនាំចេញនិងទីផ្សារអន្តរជាតិរួមមាន ជួយសម្រួលការធានាដំណើរការដ៏រលូនក្នុងការនាំចេញ និងបង្កើនឲកាន់តែមានភាពល្អប្រសើរខាងបទបញ្ញត្តិក្នុងការនាំចេញ ក៏ដូចជាធ្វើការជំរុញពង្រីកទៅទីផ្សារបរទេសឲកាន់តែទូលំទូលាយ និងសហការណ៍ជាមួយក្រសួងពាក់ព័ន្ធ ស្ថានទូត និងភ្នាក់ងារបរទេសនានា។

**<u>លក្ខខណ្ឌសមត្ថភាព និងចំណេះដឹងៈ</u>**

- មានយល់ដឹងពីវិស័យស្រូវអង្ករ ជាពិសេសផ្នែកទីផ្សារ និងការនាំចេញនាំចូល
- បានបញ្ចប់ពីសកលវិទ្យាល័យផ្នែកលក់ឬទីផ្សារឬមានបទពិសោធន៍ច្រើនឆ្នាំដែលអាចមានតម្លៃស្មើ
- មានសមត្ថភាពធ្វើការងារជាក្រុម និងក្រោមសំពាធការងារ។

## ៣. បុគ្គលិកផ្នែកពូជនិងកសិករ:

បុគ្គលិកផ្នែកពូជនិងកសិករ មានភារកិច្ចសម្របសម្រួលបញ្ហាទាំងឡាយដែលប៉ះដល់ជីវភាពរបស់កសិករដាំដុះស្រូវ រួមមាន ពូជស្រូវ ជីថ្នាំ ការបង្កើនទិន្នផល ស្តង់ដាបច្ចេកទេសដាំដុះ ប្រព័ន្ធធារាសាស្ត្រ និងទីផ្សារជាដើម។ អ្នកត្រូវបានរំពឹងក្នុងការយកផែនការសកម្មភាពនិងយុទ្ធសាស្ត្រ ដើម្បីជួយសម្រួលការអនុវត្តបង្កើនការផលិត និងភាពប្រកួតប្រជែងរបស់កសិករទូទៅ ព្រមទាំងពង្រីកទីផ្សារស្រូវរបស់កសិករ។ ការងារទាំងនេះទាមទារការចុះអនុវត្តការងារដោយផ្ទាល់តាមបណ្តាខេត្ត ហើយដើរតួនាទីជាអន្តរបុគ្គលរបស់សហព័ន្ធ ជាមួយនឹងតំណាងសហគមន៍កសិករ ក៏ដូចជា ស្ថាប័នរដ្ឋ និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា។

<u>លក្ខខ័ណ្ឌសមត្ថភាព និងចំណេះដឹង៖</u>

- មានបទពិសោធន៍យ៉ាងតិច ៣ ទៅ ៥ឆ្នាំ ក្នុងការងារកសិកម្ម ជាពិសេស ការងារពាក់ព័ន្ធនឹងការមស្របសម្រួលគម្រោងជាមួយសហគមន៍
- មានយល់ដឹងខ្ពស់អំពីការគ្រប់គ្រងផលិតកម្មស្រូវ និងពូជស្រូវ និង យល់ដឹងខ្លះៗអំពីខ្សែសង្វាក់ផ្គត់ផ្គង់ស្រូវអង្ករ
- បានបញ្ចប់សកលវិទ្យាល័យផ្នែកកសិកម្ម ឬមានបទពិសោធន៍ច្រើនឆ្នាំដែលអាចមានតម្លៃស្មើ
- អាចធ្វើការ និងសម្របសម្រួលជាមួយកំរិតសហគមន៍កសិករបាន
- យល់ដឹងខ្លះៗអីពីការគ្រប់គ្រងគំរោងអភិវឌ្ឍន៍
- មានសមត្ថភាពធ្វើការងារជាក្រុម និងក្រោមសំពាធការងារ

## ៤. តំណាងសហព័ន្ធចំនួន៥រូប ប្រចាំ៥តំបន់

តំណាងសហព័ន្ធប្រចាំតំបន់នីមួយៗ មានភារកិច្ចក្នុងការដឹកនាំនិងសម្របសម្រួលជាមួយសមាជិកតាមរយៈការប្រមូលចងក្រងនូវបណ្តារោងម៉ាស៊ីន សហគមន៍កសិករ និងផលិតកម្មពូជស្រូវ ព្រមទាំងជួយសម្របសម្រួលដោះស្រាយ ឬ រាយការណ៍មកសាខាកណ្តាលនៃសហព័ន្ធនូវបញ្ហាទាំងឡាយដែលប៉ះដល់ រោងម៉ាស៊ីន ជីវភាពរបស់កសិករ សហគមន៍កសិកម្ម ការដាំដុះស្រូវ រួមមាន ពូជស្រូវ ជីថ្នាំ ការបង្កើនទិន្នផល ស្តង់ដាបច្ចេកទេសនិងបច្ចេកវិទ្យាក្នុងការដាំដុះ ប្រព័ន្ធធារាសាស្ត្រ និងទីផ្សារជាដើម។ ហើយត្រូវអនុវត្តនូវផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់សហព័ន្ធ ដើម្បីជម្រុញការបង្កើនការផលិត និងភាពប្រកួតប្រជែងរបស់រោងម៉ាស៊ីន និងកសិករទូទៅ ព្រមទាំងពង្រីកទីផ្សារស្រូវនិងពូជរបស់កសិករ។ ការងារទាំងនេះទាមទារការចុះអនុវត្តការងារដោយផ្ទាល់តាមបណ្តាខេត្ត ហើយដើរតួនាទីជាអន្តរបុគ្គលរបស់សហព័ន្ធ ជាមួយនឹងតំណាងរោងម៉ាស៊ីន តំណាងសហគមន៍កសិករ ក៏ដូចជាស្ថាប័នរដ្ឋ និងអង្គការពាក់ព័ន្ធនានា។

<u>លក្ខខណ្ឌសមត្ថភាព និងចំណេះដឹង៖</u>

- មានបទពិសោធន៍ច្រើនឆ្នាំក្នុងការងារគ្រប់គ្រងនិងដឹកនាំការងារក្នុងវិស័យកសិកម្មជាពិសេស ដំណាំស្រូវ ការងារជាមួយរោងម៉ាស៊ីន សហគមន៍កសិករនិងផលិតកម្មពូជស្រូវ ជាដើម
- បានបញ្ចប់សកលវិទ្យាល័យផ្នែកកសិកម្ម ឬមានបទពិសោធន៍ច្រើនឆ្នាំដែលអាចមានតម្លៃស្មើ
- មានយល់ដឹងខ្ពស់ពីវិស័យស្រូវអង្ករ
- មានសមត្ថភាពធ្វើការងារជាក្រុម និងក្រោមសំពាធការងារ។

**ផុតកំណត់៖** ថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៦

**សូមទំនាក់ទំនង៖** លោក **ភុន ខេមរា** មន្ត្រីផ្នែកធនធានមនុស្ស

**អ៊ីមែល** ៖ info@crf.org.kh / phunkhemra168@gmail.com

**ទូរស័ព្ទ** ៖ ០៩២-៧២២ ៧៩៧

**អាសយដ្ឋាន៖** អគារពាណិជ្ជកម្មសូម៉ាលេខ២C ជាន់ទី៧ផ្លូវលេខ១២០ សង្កាត់ផ្សារថ្មី ll ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ។